# វប្បធម៌សន្ទនា

ជាការពិតហើយ ការសន្ទនា ជាគោលការណ៍ នៃលទ្ធិប្រជាធិបតេយ្យ ព្រោះជាមធ្យោបាយ នៃសន្តិវិធី។ សព្វអធិករណ៍ទាំងឡាយ តែងតែរកដំណោះស្រាយ ជាបឋម តាមផ្លូវសន្ទនានេះឯង ព្រោះជាសញ្ញា នៃតម្លៃរបស់មនុស្សធម៌។ ដូច្នេះ ការសន្ទនា ជាសារជាតិមូល នៃវឌ្ឍនភាពរបស់មនុស្ស ដែលវាខុសពីតិរច្ឆាន។ ម្លោះហើយ គេមិនអាចបន្ទោស ជនពីរនាក់ ឬច្រើន ធ្វើការសន្ទនា ដើម្បីបញ្ចប់ នូវជម្លោះរវាងគ្នានឹងគ្នានោះឡើយ។ តែដំណោះស្រាយ វាត្រូវមានធម្មជាតិ ជាប្រយោជន៍រួម និង ប្រយោជន៍សាធារណៈ ទើបវាមានគុណធម៌ ដែលខុសពីការសន្ទនា រវាងជនពាលទាំងឡាយ រកប្រយោជន៍ផ្ទាល់ខ្លួន ឬប្រយោជន៍ក្រុម។ ការសន្ទនាត្រឹមត្រូវ ត្រូវធ្វើឡើង ដើម្បីធ្វើគំរោង ជាកំពស់ នៃមនុស្សជាតិ ហើយវា មិនមែនជាសិទ្ធិ គឺវាជាករណីយកិច្ចតែមួយគត់។

ដកស្រង់ពីសុត្តន្តបិដក : (រុក្ខទេវតា ពោលថា) *បើអ្នកចង់រួចត្រូវរួចលោកខាងនាយ ព្រោះថាអ្នករួចឥឡូវនេះ គង់ជាប់ (ដោយបាបកម្ម) អ្នកប្រាជ្ញទាំងឡាយ មិនធ្លាប់រួចយ៉ាងនេះឡើយ ការរួចរបស់ជនពាល ឈ្មោះថាចំណងវិញទេ។*

ដូច្នេះ ការសន្ទនា ជាមួយជនពាល វាគ្រាន់តែជាដំណោះស្រាយជាចំណងវិញនោះឯង ព្រោះជនពាល វាគ្មានគោលបំណងល្អជាដាច់ខាត៕

**ឧប សៅ សង្ហា     គំនិត     ១២ មិថុនា ២០១៨**